# ការរុករក និងការអភិវឌ្ឍរ៉ែ
# ហានិភ័យ និង រង្វាន់

រ៉ូឌែរិក អ៊ិកហ្គើត

សន្និសីទអន្តរជាតិ ស្តីពីអាជីវកម្មរ៉ែ

"ឱកាសសម្រាប់កម្ពុជា"

ថ្ងៃ ទី ២៦_២៧ ខែ ឧសភា ឆ្នាំ ២០១០

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

# ទម្រង់រួមនៃ "ការរុករករ៉ែនិងអភិវឌ្ឍន៍រ៉ែ "

- *ចរិតលក្ខណៈ*
- តើកើតឡើងនៅកន្លែងណាខ្លះ
- ផ្តល់ហិរញ្ញប្បទានយ៉ាងដូចម្តេចខ្លះ
- "ទម្លាប់អនុវត្តល្អៗ" ក្នុងគោលនយោបាយសាធារណៈ

# ការរុករករ៉ែ និងអភិវឌ្ឍន៍រ៉ែ...

- ...គឺជាការវិនិយោគ
- ពួកគេប្រកួតប្រជែងជាមួយឱកាសផ្សេងទៀតនៃការវិនិយោគ
- កម្រិត និងទីតាំងវិនិយោគត្រូវបានកំណត់ដោយការរំពឹងទុកលើការចំណាយ និងផលចំណូល ដែលកែតម្រូវទៅតាមពេលវេលា និងហានិភ័យ

# កត្តានានាដែលកំណត់អំពីការកំពឹងទុកលើផលចំណូល ការចំណាយ និងហានិភ័យ

- កត្តាភូគព្ភសាស្ត្រ
  - តើមានធនធានរ៉ែដែរឬទេ ក្នុងបរិមាណប៉ុន្មាន មានកម្រិតអត្រាប៉ុន្មាន និងគុណភាពកម្រិតណា សម្រាប់ការធ្វើលោហុស្សាកម្ម?
- កត្តាបច្ចេកទេស
  - តើគេអាចជីកយក និងកែច្នៃធនធានរ៉ែបានឬទេ ដោយប្រើបច្ចេកវិទ្យាអ្វី?
- កត្តាបរិស្ថាន សង្គម និងនយោបាយ
  - តើគេអាចជីកយកធនធានរ៉ែតាមមវិធីនានាដែលមានសង្គតិភាពជាមួយការប្រាថ្នារបស់ ប្រជាជាតិ ដើម្បីឱ្យមានគុណភាពលើផ្នែកបរិស្ថាន និងផ្តល់ផលមកលើសហគមន៍មូលដ្ឋានដែរឬទេ? និងតាមវិធី ដែលមានលក្ខណ:ស្របគ្នាជាមួយគោលនយោបាយ សាធារណ:និងបរិស្ថាននយោបាយ ដែរឬទេ?
- កត្តាសេដ្ឋកិច្ច
  - ជារួម តើគេអាចជីកយកធនធានរ៉ែណាមួយ ដែលអាចផ្តល់ផលចំណេញដែរឬទេ?

# ការស្រាវជ្រាវ និងអភិវឌ្ឍន៍...

- ...ទាំងអស់នេះជាដំណើរការមួយនៃការប្រមូលព័ត៌មានដែលមាន ច្រើនដំណាក់កាល

# ដំណាក់កាលនានាក្នុងការផ្គត់ផ្គង់រ៉ែ

1. ការរុករកនៅដំណាក់ដំបូង និងការរុករកនៅដំណាក់កាលក្រោយមកនៃការអភិវឌ្ឍ → កំណត់រក និងវាយតម្លៃជម្រករ៉ែ
2. ការអភិវឌ្ឍន៍ជម្រករ៉ែ → បង្កើតគំរូប្លង់ និងសាងសង់អណ្តូងរ៉ែ
3. ការធ្វើអាជីវកម្មរ៉ែ → ផលិតរ៉ែ និងកំហាប់ (ឬទម្រង់ផ្សេងនៃផលិតផលពាក់កណ្តាល សម្រេច)
4. ការកែច្នៃតាមបែបលោហុស្សកម្ម → ផលិតចេញជាលោហៈដែលត្រូវចម្រាញ់
5. ការកែច្នៃ និងផលិត → ប្រែក្លាយលោហៈដែលបានចម្រាញ់រួច ឱ្យទៅជាផលិតផលសម្រេច

*ទស្សនវិស័យអំពីជម្រករ៉ែ:* គេត្រូវរកឃើញជម្រករ៉ែមុននឹងអាចធ្វើអាជីវកម្មបាន។

*ទស្សនវិស័យរបស់ក្រុមហ៊ុន:* ក្រុមហ៊ុនអាចសម្រេចចិត្តចូលក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ក្នុង ដំណាក់កាលណាមួយនៃផលិតកម្ម

# ទស្សនវិស័យរបស់ក្រុមហ៊ុនៈ តើត្រូវចូលត្រង់ណា នៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់?

| | ការរុករកនៅដំណាក់កាលដំបូង | ការរុករកនៅដំណាក់កាលក្រោយមក | អភិវឌ្ឍន៍ជម្រករ៉ែ | ដំណើរការអណ្តូងរ៉ែ |
|---|---|---|---|---|
| រយៈពេលមុនធ្វើអាជីវកម្ម | វែង → ខ្លី (សកម្មភាពជាបន្តពី ៥-១៥ឆ្នាំ ចាប់ពីការចាប់ផ្តើមរុករកនៅមូលដ្ឋាន) | | | |
| ហានិភ័យភូគព្ភសាស្ត្រ | ខ្ពស់ → ទាបជាង | | | |
| ផ្ទៃដី | ធំ → តូចជាង | | | |
| ហានិភ័យលើការចំណាយនិងសេដ្ឋកិច្ច | ទាប → ខ្ពស់ជាង | | | |
| លទ្ធភាពចំណេញ | ខ្ពស់ → ទាបជាង | | | |
| ហានិភ័យនយោបាយ | ទាប → ខ្ពស់ជាង (អំណាចចរចា ប្តូរទៅខាងផ្នែករដ្ឋាភិបាល នៅពេលណាដែលការធ្វើអាជីវកម្មរ៉ែចាប់ផ្តើម ការរុករកជាសកម្មភាពដែល "ងាយដកខ្លួន" ចេញបាន) | | | |

# ការរុករកនៅដំណាក់កាលដំបូង

| | |
|---|---|
| សកម្មភាព | ការសិក្សាឯកសារមានស្រាប់ ការជ្រើសរើសទីតាំង ការទទួលបានចំណែកដី ការសិក្សាតំបន់ (ភូមិសាស្ត្រ គីមីដី រូបសាស្ត្រដី) ការធ្វើឱ្យសហគមន៍ពាក់ព័ន្ធជាលើកដំបូង |
| ផ្ទៃដី (1.000 $km^2$) | 100-1000 |
| ចំណាយ (លានដុល្លារ) | រហូតដល់ 10លាន |
| លទ្ធផលដែលអាចបានពីការសិក្សា | ផ្តោតលើការធ្វើអត្តសញ្ញាណសម្រាប់ធ្វើការវិភាគពិស្តារនាពេលក្រោយ |

# ការរុករកនៅដំណាក់កាលក្រោយមកនៃការអភិវឌ្ឍ

| | |
|---|---|
| សកម្មភាព | ការវាយតម្លៃលំអិតលើកន្លែងជាគោលដៅ (ភូគព្ភសាស្ត្រ គីមីភូគព្ភសា-ស្ត្រ រូបសាស្ត្រភូគព្ភសាស្ត្រ) ខួង ជីករណ្តៅ កំណត់ព្រំប្រទល់កំណប់រ៉ែ ការធ្វើលោហកម្មដំបូង ការប្រមូលទិន្នន័យគោលអំពីបរិស្ថាន និង សង្គម ការធ្វើឱ្យសហគមន៍ចូលរួម |
| ផ្ទៃដី (1.000 $km^2$) | 1-10 |
| ចំណាយ (លានដុល្លារ) | រហូតដល់ 100 លាន |
| លទ្ធផលដែលអាចបានពីការសិក្សា | - ការសិក្សាទំហំ : ប៉ាន់ស្មានអំពីធនធាន ប៉ាន់ស្មានអំពីរបត់នៃទំហំ ចំណាយ គំនិតទូទៅអំពីអ្វី ដែលអាជីវកម្មរ៉ែអាចធ្វើទៅបាន<br>- ការសិក្សាលទ្ធភាពដំបូង : កាន់តែលំអិតជាងការសិក្សាទំហំ និងដែលរួមបញ្ចូលកែលម្អលើ ការប៉ាន់ប្រមាណអំពីធនធាន ការបង្កើតគំរូ និង វិស្វកម្មដំបូងអំពីអាជីវកម្មរ៉ែ និងការប៉ាន់ស្មានដំបូងអំពីការចំណាយ ) |

# ការអភិវឌ្ឍជម្រករ៉ែ

| | |
|---|---|
| សកម្មភាព | ការខួងដើម្បីវិភាគលំអិត កសាងផែនការអាជីវកម្មរ៉ែ ការសាកល្បងលោ-ហុស្សាកម្ម បន្តវាយតម្លៃ បរិស្ថាន បន្តធ្វើឱ្យសហគមន៍ចូលរួមពាក់ព័ន្ធ |
| ផ្ទៃដី (1.000 km$^2$) | 1 |
| ចំណាយ (លានដុល្លារ) | ប្រែប្រួល អាចច្រើនជាង 1 ពាន់លានដុល្លារអាមេរិក |
| លទ្ធផលដែលអាចបានពីការសិក្សា | - ដាក់ពាក្យសុំអាជ្ញាប័ណ្ណ និងការអនុញ្ញាតនានាដែលចាំបាច់<br>- ការសិក្សាលទ្ធភាព : ប៉ាន់ស្មានកំណប់រ៉ែ បង្កើតប្លង់អណ្តូងរ៉ែ និងរោងចក្រ ប៉ាន់ស្មានលំអិត អំពីវិស្វកម្ម និងការចំណាយ វាយតម្លៃពេញលេញខាងបច្ចេកទេសនិងសេដ្ឋកិច្ច ហិរញ្ញប្បទាន<br>- ការសម្រេចថា "ទៅមុខ/ឬមិនទៅ" លើការអភិវឌ្ឍអណ្តូងរ៉ែ" |

# ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម

| | |
|---|---|
| ការរុករកដំបូង | - តាមធម្មតា មានឥទ្ធិពលអប្បបរមា បណ្តាលពីការអង្កេតពីលើអាកាស និងការសិក្សានៅ លើផ្ទៃដី ក្នុងកម្រិតតំបន់ |
| ការរុករកនៅដំណាក់កាលក្រោយមក | - កាន់តែច្រើន ប៉ុន្តែនៅតែមានត្រឹមឥទ្ធិពលបង្គួរ<br>- កសាងផ្លូវ ចរាចរ ខ្ទង់ ជីករណ្តៅ ។ល។ អាចមានឥទ្ធិពលលើខ្យល់ រុក្ខជាតិ សត្វ ដី ទឹក<br>- ឥទ្ធិពលភាគច្រើនអាចកាត់បន្ថយមកត្រឹមការចំណាយលើឧត្តម្ភាគចក្រ ជួសជុលក្រោយខ្ទង់ និងសកម្មភាពផ្សេងៗទៀត |
| ការអភិវឌ្ឍជម្រករ៉ែ និងការយករ៉ែ | - ឥទ្ធិពលកាន់តែខ្លាំងឡើង<br>- បរិស្ថាន : ការសាងសង់ ការយករ៉ែ កែច្នៃ ការចោលសំណល់ និងទឹកសំអុយ មានឥទ្ធិពល មកលើខ្យល់ រុក្ខជាតិ សត្វ ដី ទឹក<br>- សង្គម : មនុស្សកាន់តែច្រើនអាចចូលមក ហើយការប្រែប្រួលជាច្រើនក្នុង សហគមន៍ អាច បង្កជាការប្រឈមនានា<br>- ឥទ្ធិពលជាច្រើន អាចកាត់បន្ថយ និងគ្រប់គ្រងបាន ប៉ុន្តែមានការប្រែប្រួល ខ្លះដែលមិនអាចជៀសវាងបាន និងផ្លាស់ប្តូរជាអចិន្ត្រៃយ៍។ |

# ទម្រង់រួមនៃ "ការរុករក និងអភិវឌ្ឍន៍រ៉ែ"

- សំណុំលក្ខណៈ
- *តើកើតឡើងនៅទីណាខ្លះ ...*

  *...អាស្រ័យលើ ក. សក្តានុពលភូគព្ភសាស្ត្រ និង ខ. បរិយាកាសនៃការវិនិយោគ*
- តើផ្តល់ហិរញ្ញប្បទានយ៉ាងដូចម្តេចខ្លះ
- "ទម្លាប់អនុវត្តល្អៗ"ខាងគោលនយោបាយសាធារណៈ

# ទស្សនទាននានាអំពីសក្តានុពលភូគព្ភសាស្ត្រ

- ទស្សនទាននានា បានផ្អែកលើៈ
  - ចំណេះដឹងផ្នែកភូគព្ភសាស្ត្រអំពីសកម្មភាពមិនមែនជីកយករ៉ែ (ដូចជា ការសាងសង់ផ្លូវថ្នល់ ការវាយតម្លៃអំពីគ្រោះថ្នាក់ផ្នែកភូគព្ភសាស្ត្រ ជាដើម)
  - ការរុករក និងការជីកយករ៉ែកាលពីអតីតកាលនិងបច្ចុប្បន្នកាល
  - ការស្រាវជ្រាវ និងព័ត៌មានវិទ្យាសាស្ត្រផ្នែកប្រថពីដែលបានមកពីស្ថាប័នអង្កេតភូគព្ភសាស្ត្រសាធារណៈ
    - ព័ត៌មានវិទ្យាសាស្ត្រផ្នែកប្រថពីគឺជាសម្បត្តិសាធារណៈ
    - ជាកាតាលីកររមួយ (ផ្សព្វផ្សាយដំណឹង ផ្តល់សញ្ញាឱ្យដឹង)
- ការរុករកនៅកន្លែងមួយមិនដែលធ្វើ "ម្តងសម្រាប់ប្រើប្រាស់គ្រប់កន្លែងនោះទេ"
  - អ្នករុករកផ្សេងគ្នាបកស្រាយទិន្នន័យតែមួយមិនដូចគ្នាទេ
  - ការយល់ដឹងបែបវិទ្យាសាស្ត្រអំពីកំណប់រ៉ែកាន់តែមានលក្ខណៈប្រសើរឡើង ទៅតាមពេលវេលា ការប្រែប្រួលបច្ចេកវិទ្យា ការប្រែប្រួលលក្ខខណ្ឌសេដ្ឋកិច្ច និងនយោបាយ

# បរិយាកាសវិនិយោគ និងរដ្ឋាភិបាល

- ការពិចារណាទូទៅ (ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងនយោបាយ ប្រព័ន្ធច្បាប់និងធនាគារ វិធានសារពើពន្ធ ។ល។)
- គោលនយោបាយរ៉ែ
  - មុខងាររបស់រដ្ឋ
  - លទ្ធភាពទទួលបានសិទ្ធិលើដីធ្លី និងធនធានរ៉ែ
  - សុវត្ថិភាពលើសិទ្ធិកាន់កាប់
  - សហគមន៍មូលដ្ឋាន
  - កិច្ចការពារបរិស្ថាន (ក្នុងពេលប្រតិបត្តិការ ក្រោយពេលបិទការដ្ឋាន)
  - ការពិចារណាផ្នែកពាណិជ្ជកម្ម (ដូចជា លក្ខណ្ឌក្នុងការផលិតនៅដំណាក់កាលចុងក្រោយនៃខ្សែសង្វាក់ផលិតកម្ម ការរកទីផ្សារ រូបិយប័ណ្ណបរទេស ការបង្វែរប្រាក់ចំណេញ សិទ្ធិនៃការផ្ទេរប្រាក់)
  - ការយកពន្ធលើការអាជីវកម្មរ៉ែ

# ការយកពន្ធពីការធ្វើអាជីវកម្មរ៉ែ

- មូលហេតុមួយចំនួនដែលនាំឱ្យមានការយកពន្ធលើអាជីវកម្មរ៉ែខុសពីសកម្មភាពដទៃ
  - រដ្ឋាភិបាលជាម្ចាស់លើធនធានរ៉ែនៅក្រោមដី
  - អាជីវកម្មរ៉ែនាំមកនូវផលខុសគ្នា ឬ ផលលើសពីសេចក្តីត្រូវការផ្សេងគ្នា
    - អំណោយពីធម្មជាតិ សមត្ថភាពក្នុងការទូទាត់ បែងចែកប្រាក់ចំណូលសារជាថ្មី កាត់បន្ថយភាពក្រីក្រ
  - ការធ្វើអាជីវកម្មរ៉ែធ្វើឱ្យបាត់បង់ធនធានដែលមិនអាចកកើតឡើងវិញ
    - ធ្វើឱ្យមាននិរន្តរភាពប្រាក់ចំណេញនៃអាជីវកម្មរ៉ែក្រោយពេលបញ្ចប់សកម្មភាពយករ៉ែ
    - វិនិយោគតាមទម្រង់ដទៃនៃមូលធនដែលមាននិរន្តរភាព
      - សុខភាពមនុស្ស
      - ការអប់រំ
      - ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ
      - ឧស្សាហកម្មដទៃទៀត

# ការយកពន្ធពីការធ្វើអាជីវកម្មរ៉ែ (ត)

- ប្រភេទ
  - ឯកត្តាផលិតកម្ម (គិតជាទម្ងន់)
  - តម្លៃដុល
  - ចំណេញសុទ្ធ
  - ការទូទាត់ប្រាក់រង្វាន់ជាមុន
- ភាពខុសគ្នារវាងប្រភេទពន្ធផ្សេងៗ
  - កត្តាលើកទឹកចិត្តចំពោះការវិនិយោគលើការរុករក និងការធ្វើអាជីវកម្មរ៉ែ
  - ការបែងចែកហានិភ័យរវាងក្រុមហ៊ុន និងរដ្ឋាភិបាល
  - ការកំណត់ពេលវេលា ស្ថិរភាព លទ្ធភាពព្យាករណ៍ចំណូលរបស់រដ្ឋាភិបាល
  - ភាពងាយស្រួល និងចំណាយលើការអនុវត្ត

# ទម្រង់រួមនៃ "ការរុករក និងអភិវឌ្ឍន៍រ៉ែ"

- សំណុំលក្ខណៈ
- ទីកន្លែងមានការរុករក និងអភិវឌ្ឍន៍ធនធានរ៉ែ
- *តើផ្តល់ហិរញ្ញប្បទានបែបណា សម្រាប់សកម្មភាពទាំងពីរនេះ?*
- "ទម្លាប់អនុវត្តល្អ" ខាងគោលនយោបាយសាធារណៈ

# ចំណុចទូទៅ

- ប្រភពហិរញ្ញវត្ថុ
  - មូលនិធិផ្ទៃក្នុង
  - ភាគហ៊ុន
  - បំណុល
- ការរុករ៉ែភាគច្រើន
  - មូលនិធិផ្ទៃក្នុង (បណ្តាក្រុមហ៊ុនដែលមានអណ្តូងរ៉ែសកម្ម)
  - ភាគហ៊ុន (ក្រុមហ៊ុនតូចៗដែលធ្វើការស្រាវជ្រាវរុករក)
- ការអភិវឌ្ឍរ៉ែភាគច្រើន
  - ចម្រុះរវាងភាគហ៊ុន និងបំណុល

# ភាគហ៊ុន

- ក្រៅទីផ្សារ
  - មូលធនវិនិយោគដែលមានហានិភ័យខ្ពស់
  - ការដាក់ទុនរបស់ឯកជន
  - វិនិយោគរួមគ្នា (ដូចជា ក្រុមហ៊ុនរ៉ៃផ្តល់មូលនិធិសម្រាប់សកម្មភាពផ្សេងៗរបស់ក្រុមហ៊ុនតូចៗដែលធ្វើការស្រាវជ្រាវរុករកជាថ្នូរនឹងភាពជាម្ចាស់លើភាគហ៊ុនមួយផ្នែក)
  - ការផ្តល់ហិរញ្ញប្បទានដែលផ្អែកលើសួយសារ
- ទីផ្សារ
  - ការដាក់លក់ពីដំបូងតាមការកំណត់ថ្លៃជាសាធារណជន
  - ការបោះផ្សាយសិទ្ធិលើភាគហ៊ុននាពេលក្រោយ

ប្រភព: Guj (2006)

# បំណុល

- បំណុលរបស់ក្រុមហ៊ុនៈ ប្រាក់កម្ចីផ្តល់ឱ្យក្រុមហ៊ុនទាំងមូល
- ហិរញ្ញប្បទានគម្រោងៈ ប្រាក់កម្ចីផ្តល់ឱ្យគម្រោង គ្មានសិទ្ធិទាមទារទ្រព្យសម្បត្តិ ផ្សេងទៀតរបស់ក្រុមហ៊ុនឡើយ

ប្រភពៈ Guj (2006)

# ទម្រង់រួមនៃ "ការរុករក និងអភិវឌ្ឍន៍រ៉ែ"

- សំណុំលក្ខណៈ
- តើការរុករក និងអភិវឌ្ឍន៍ធនធានរ៉ែធ្វើឡើងនៅកន្លែងណាខ្លះ
- តើផ្តល់ហិរញ្ញប្បទានបែបណាសម្រាប់សកម្មភាពទាំងពីរនេះ
- *"ទម្លាប់អនុវត្តល្អ " ខាងគោលនយោបាយសាធារណៈ*

# "ទម្លាប់អនុវត្តល្អ "ខាងគោលនយោបាយសាធារណៈ

- ផ្តល់ព័ត៌មានវិទ្យាសាស្ត្រភូគព្ភសាស្ត្រថ្មីៗ និងសំខាន់ៗ
- បែងចែកដីធ្លីបានសមស្របបំផុត ដោយគិតគូរអំពីបញ្ហាសេដ្ឋកិច្ច សង្គម និងបរិស្ថាន
- ផ្តល់អាជ្ញាប័ណ្ណច្បាស់លាស់ មានប្រសិទ្ធិភាព មានតម្លាភាព
- សិទ្ធិកាប់កាប់ដីធ្លីមានសុវត្ថិភាព
- របបពន្ធមានលក្ខណៈប្រកួតប្រជែងជាអន្តរជាតិ
- ផ្តល់បានគ្រប់គ្រាន់នូវអ្នកប្រកបវិជ្ជាជីវៈដែលមានគុណវុឌ្ឍិ
- វិធានបរិស្ថានគ្រប់គ្រាន់ និងមានសង្គតិភាព
- បែងចែកប្រាក់ចំណេញបានសមស្របបំផុត

ប្រភព: ABARE (2007)

# "ទម្លាប់អនុវត្តល្អ" ខាងអភិបាលកិច្ចសេដ្ឋកិច្ច

- សង្គតិភាព គណនេយ្យភាព និងសមត្ថភាពរដ្ឋបាលនៅទូទាំងវិស័យសេដ្ឋកិច្ច
- អព្យាក្រឹតភាពដែលមានលក្ខណៈប្រកួតប្រជែងនៅទូទាំងវិស័យ
- កិច្ចសម្រួលរចនាសម្ព័ន្ធធុរកិច្ចដែលមានលក្ខណៈបត់បែន
- បរិយាកាសវិនិយោគបរទេសមួយដែលគ្មានការកៀបសង្កត់
- ទីផ្សារសេរីគ្មានរបាំងចំពោះពាណិជ្ជកម្ម
- មានលទ្ធភាពចូលទៅកាន់ទីផ្សារមូលធនក្នុងស្រុកនិងក្នុងពិភពលោកដោយគ្មានជាប់កម្រិតកំណត់
- វិនិយោគគ្រប់គ្រាន់លើហេដ្ឋារចនាសម្ព័ន្ធ

ប្រភព: ABARE (2007)

ព័ត៌មានសម្រាប់ទាក់ទង:

Roderick G. Eggert

សាស្ត្រាចារ្យ និងប្រធានផ្នែក

ផ្នែកសេដ្ឋកិច្ចនិងធុរកិច្ច

មហាវិទ្យាល័យរ៉ែកូឡូរ៉ាដូ

Golden, Colorado
USA 80401

ទូរស័ព្ទ:+1 303 273 3981

អ៊ីម៉េល: reggert@mines.edu